ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បច្ចេកទេសដាំដំណាំត្រសក់ចំណារ ដែលធន់ទៅ នឹងការប្រែប្រួលអាកាសធាតុ







ភ្នំពេញ ខែ ឧសភា ឆ្នាំ ២០១៧


រៀបចំដោយ : កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ( ASPIRE)

ឧបត្ថម្ភដោយ : រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម(IFAD)

# មាតិកា

ទំព័រ


**មាតិកា** ..... 1

**សេចក្តីថ្លៃងអំណរគុណ** ..... 2

**មេរៀនទី ១: ការជ្រើសរើសទីតាំង និងការរៀបចំដី** ..... 3

**មេរៀនទី ២: ការធ្វើពេថបណ្តុះកូន និងការបណ្តុះគ្រាប់** ..... 8

**មេរៀនទី ៣: ការដាំកូនត្រសក់** ..... 11

**មេរៀនទី៤ : របៀបស្រោចស្រពដោយប្រព័ន្ធដំណក់ទឹក** ..... 13

**មេរៀនទី៥ : ការថែទាំ** ..... 16

**មេរៀនទី៦ : បច្ចេកទេសគ្រប់គ្រង ក្រោយការប្រមូលផលត្រសក់** ..... 20

**មេរៀនទី ៧ : ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូចផ្លែកដំណាំបន្លែ** ..... 21

**ឯកសារយោង** ..... 29

# មេរៀនទី ១: ការជ្រើសរើសទីតាំង និងការរៀបចំដី

**១. គោលបំណងនៃវគ្គបណ្តុះបណ្តា** ផ្តល់ចំណេះដឹងដល់សិក្ខាកាមអំពី៖

- ការរៀបចំដី ដាំដំណាំក្នុងរដូវប្រាំង និងវស្សា
- ការជ្រើសរើសគ្រាប់ពូជដែលធន់ និងការប្រែប្រួលអាកាសធាតុ ដើម្បីសាប និងទទួលបានកូនដំណាំយ៉ាងល្អសម្រាប់ស្ទូង
- សារៈប្រយោជន៍ ការគ្របកៅស៊ូ និងពង្រាយចំបើងលើរង ដំណាំ ដែលអាចទប់ទល់ នឹងការប្រែប្រួលអាកាសធាតុ

## ២. ការជ្រើសរើសទីតាំង

- ក្បែរប្រភពទឹក
- រដូវប្រាំង នៅក្បែរផ្ទះ ក្នុងស្រែក្រោយពីប្រមូលផលស្រូវ
- រដូវវស្សា ដីខ្ពស់មិនលិចទឹក ដីរាបស្មើ ឬជម្រាលមិនសូវខ្លាំង
- ដីធូរ មានជីជាតិល្អ ជ្រាបទឹកល្អ ជៀសវាងដីគ្រួស ដីឥដ្ឋ ដីខ្សោះជីជាតិអាចធ្វើឲ្យដីប្រសើរដោយ ជីក្រោល ឬកំប៉ុស្ត
- មានរបងព័ទ្ធជុំវិញ មិនឆ្ងាយពីផ្ទះ
- បង្ហូរទឹកចេញបាន ដីមិនសើមពេកនារដូវភ្លៀង ទីកន្លែងស្រឡះមានខ្យល់ល្អ



ការរៀបចំសួនបន្លែ

## ៣. ការជ្រើសរើសគ្រាប់ពូជ

- ពូជសុទ្ធអត្រាដុះលើសពី៨០ភាគរយ
- ពូជធន់និងអាកាសធាតុ សត្វល្អិត ជម្ងឺ
- អាយុកាលខ្លីសមស្របតាមតំបន់
- ផ្តល់ទិន្នផលខ្ពស់